រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។ /

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧៤៦ អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការផ្ដល់មេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ ០៣រូប និងភ្នាក់ងារ ០១រូប ដែលមានស្នាដៃល្អក្នុងការចូលរួមស្ថាបនាកំណាត់ផ្លូវជាតិ លេខ១ (ភ្នំពេញ-អ្នកលឿង) សម្រេចលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម :-

១-លោក **សួន សុខុម**	អនុប្រធានការិយាល័យ នៃមជ្ឈមណ្ឌលគ្រឿងចក្រធំ១ ទទួលបន្ទុកតំរោងស្ពានឡើងវិញ កំណាត់ផ្លូវជាតិ លេខ ១
២-លោក **គ្រាត់ ចន្ថា**	អនុប្រធានការិយាល័យ នៃមជ្ឈមណ្ឌលគ្រឿងចក្រធំ១ ទទួលបន្ទុកតំរោងស្ពានឡើងវិញ កំណាត់ផ្លូវជាតិ លេខ ១
៣-លោកស្រី **ផេន សុចិន្តា**	មន្ត្រី នៃមជ្ឈមណ្ឌលគ្រឿងចក្រធំ១ ទទួលបន្ទុកតំរោងស្ពានឡើងវិញកំណាត់ផ្លូវជាតិ លេខ ១
៤-លោក **សៀក ម៉េងគាន**	ភ្នាក់ងារកម្មវិធី ទទួលបន្ទុកផ្នែកហេដ្ឋារចនាសម្ព័ន្ធ

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...០០៥...សហវ.....

សារាចរណែនាំ

ស្តីពីការអនុវត្តថវិការាជធានី ខេត្ត ឆ្នាំ ២០១០

ច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ។ ដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ២២៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ និងអនុក្រឹត្យលេខ ២២៨ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការបែងចែក ចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។ ដើម្បីអោយការអនុវត្ត ច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ មានដំណើរការប្រកបដោយ ភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាពខ្ពស់ និងសំរេចបានតាមគោលដៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំលើការអនុវត្តថវិការបស់រាជធានី ខេត្ត សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ដែលមានភ្ជាប់ជាប់លំដាប់ដូចតទៅ ៖

ក. អំពីចំណូល

១. ចំណូលសារពើពន្ធ

ចំពោះមុខសញ្ញាចំណូលសារពើពន្ធ ដែលច្បាប់បានអនុញ្ញាតអោយប្រមូលសម្រាប់ ជាគុណប្រយោជន៍នៃថវិការាជធានី ខេត្ត រាជធានី ខេត្ត ត្រូវជំរុញ និងតាមដានការអនុវត្តគោលនយោបាយ និងនីតិវិធីប្រមូលចំណូលរបស់មន្ត្រីពន្ធដារអោយបានត្រឹមត្រូវតាមបទប្បញ្ញត្តិជាធរមាន និងត្រូវរួមចំណែកដាក់ចេញវិធានការ ជាក់ស្តែងសម្រាប់ប្រភេទពន្ធដារនីមួយៗ ដើម្បីតម្រូវអោយអ្នកជាប់ពន្ធ បង់ពន្ធបានត្រឹមត្រូវគ្រប់គ្រាន់ និងទាន់ពេលវេលា ។ ទន្ទឹមនោះ រាជធានី ខេត្ត ត្រូវចាត់អោយមានមន្ត្រីទទួលបន្ទុកប្រមូលទិន្នន័យ ស្ថិតិ និងកម្រងព័ត៌មាន ដែលជាមូលដ្ឋានក្នុងការប្រមូលពន្ធដារ សម្រាប់ជាគុណប្រយោជន៍ដល់ថវិការាជធានី ខេត្ត ដើម្បីជួយដល់មន្ត្រីពន្ធដាក្នុងការប្រមូលចំណូល និងធ្វើជាឯកសារយោងក្នុងការរៀបចំគំរោងចំណូលពន្ធដារ សម្រាប់ឆ្នាំនីមួយៗ ។

២. ចំណូលមិនមែនសារពើពន្ធ

ចំពោះចំណូលមិនមែនសារពើពន្ធ ដែលច្បាប់បានអនុញ្ញាតអោយប្រមូល សម្រាប់ថវិការាជធានី ខេត្ត រាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់ស្រាវជ្រាវកំណត់មុខសញ្ញាចំណូល ដែលត្រូវប្រមូលបង់ចូលរតនាគារអោយអស់ មិនត្រូវទុកចំណូលខ្លះ នៅដោយឡែក សម្រាប់ចំណាយដោយឡែកក្រៅពីគំរោងចំណាយប្រចាំឆ្នាំឡើយ ។

[illegible] សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ [illegible] ទូរសារ [illegible]
Phone: 855-23-724 664 Fax: 855-23-427 798
[illegible]

ចំពោះចំណូលមិនមែនសារពើពន្ធដទៃទៀត ដែលរាជធានី ខេត្តបានប្រមូលក្រៅពីការអនុញ្ញាតដោយច្បាប់ ក៏ត្រូវបង់ចូលថវិការាជធានី ខេត្តដែរ ជៀសវាងទុកចំណូលនោះដោយឡែកសម្រាប់ចំណាយដោយឡែក គ្មានតម្លាភាព។

ចំពោះមុខសញ្ញាចំណូលដែល បានកំណត់រួចហើយ លើក្នុងលក្ខណៈដែលត្រូវប្រមូលតាមវិធីដេញថ្លៃជាសាធារណៈនោះ ត្រូវធ្វើអោយមានតម្លាភាពពិតប្រាកដ មិនត្រូវបង្កើតការដេញថ្លៃក្លែងក្លាយភាពនោះទេ ទន្ទឹមនោះ ត្រូវយកចិត្តទុកដាក់ជំរុញការបង់ចំណូលអោយបានត្រឹមត្រូវតាមការកំណត់ដែលមានចែងក្នុងកិច្ចសន្យា ។

ដោយឡែក សម្រាប់ខេត្តបាត់ដំបង និងខេត្តសៀមរាប ត្រូវជួយបង្កគ្រប់លក្ខណៈសម្បត្តិអោយការប្រមូលចំណូលពីច្រកចេញចូលតែមួយរបស់ក្រុងបាត់ដំបង និងក្រុងសៀមរាបប្រព្រឹត្តទៅបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព ។

៣. ចំណូលឧបត្ថម្ភពីថវិការដ្ឋ

ចំពោះរាជធានី ខេត្ត ដែលត្រូវបំពេញគុណភាពដោយការឧបត្ថម្ភពីថវិការដ្ឋ ទោះបីបានកត់ត្រាតួលេខចំណូលឧបត្ថម្ភពីថវិការដ្ឋ នៅក្នុងគំរោងថវិការបស់ខ្លួនក៏ដោយ ក៏មិនមានន័យថា ថវិការដ្ឋត្រូវតែដាច់ខាតឧបត្ថម្ភតាមចំនួននោះទេ ។ ចំណូលឧបត្ថម្ភពីថវិការដ្ឋ គឺត្រូវពិនិត្យឧបត្ថម្ភជូនរាជធានី ខេត្ត ដោយផ្អែកទៅតាមស្ថានភាពជាក់ស្តែងនៃគុណភាពថវិការដ្ឋ និងទៅតាមសភាពការណ៍ជាក់ស្តែងនៃការអនុវត្តចំណូល ចំណាយថវិការបស់រាជធានី ខេត្ត ។

៣.១ ចំណូលឧបត្ថម្ភគុណភាពពីថវិការដ្ឋ

ចំពោះចំណូលនេះ រាជធានី ខេត្ត ត្រូវធ្វើសំណើសុំឧបត្ថម្ភគុណភាពប្រចាំត្រីមាសនីមួយៗ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈក្រសួងមហាផ្ទៃ ។ នៅដើមត្រីមាសទី ១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងផ្តល់ថវិកាឧបត្ថម្ភគុណភាពជូនរាជធានី ខេត្ត ដោយមិនចាំបាច់មានការស្នើសុំទេ ។ ដោយឡែកសំរាប់ត្រីមាសទី ២ ទី ៣ និងទី ៤ រាជធានី ខេត្ត ត្រូវធ្វើសំណើសុំថវិកាឧបត្ថម្ភគុណភាពនៅដើមខែ នៃចុងត្រីមាសមុន សម្រាប់ត្រីមាសបន្ទាប់ដោយភ្ជាប់មកជាមួយនូវឯកសារជាមូលដ្ឋាននៃការស្នើសុំឧបត្ថម្ភគុណភាពដូចជា :

- របាយការណ៍ចំណូល ចំណាយជាក់ស្តែងដែលបានអនុវត្តរួច
- របាយការណ៍ប៉ាន់ស្មានចំណូល ចំណាយប្រចាំត្រីមាសបន្ទាប់
- តារាងក្របខ័ណ្ឌមន្ត្រីរាជការ

៣.២ ចំណូលឧបត្ថម្ភពីថវិការដ្ឋសំរាប់វិនិយោគសាធារណៈ

ចំណូលនេះ គ្រាន់តែជាការផ្ទេរឥណទានថវិការដ្ឋសំរាប់អនុវត្តនូវកម្មវិធីចំណាយវិនិយោគសាធារណៈ នៅក្នុងថវិការាជធានី ខេត្ត ដូច្នេះពេលស្នើសុំគឺរាជធានី ខេត្ត ត្រូវធ្វើសំណើត្រង់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែម្តង ។ ការស្នើនេះ ចែកចេញជាពីរយ៉ាង ៖

ទី១. ឧបត្ថម្ភសម្រាប់ចូលនិធិបដិភាគ

ផ្អែកលើតួលេខដែលបានគ្រោងក្នុងសៀវភៅថវិការាជធានី ខេត្ត ឬ ប្រកាសបន្ថែមឥណទានត្រូវធ្វើសំណើដោយភ្ជាប់មកជាមួយនូវគំរោងកម្មវិធីវិនិយោគសាធារណៈ នៃហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលត្រូវអនុវត្តនៅរាជធានី ខេត្តរបស់ខ្លួន ។

ទី២. ឧបត្ថម្ភវិនិយោគដោយថវិការដ្ឋ

ផ្អែកលើតួលេខដែលបានគ្រោងក្នុងសៀវភៅថវិការាជធានី ខេត្ត ឬប្រកាសបន្ថែមឥណទាន ត្រូវធ្វើសំណើដោយភ្ជាប់មកជាមួយនូវឯកសារដែលបានធ្វើលទ្ធកម្មសាធារណៈរួចតាមការដ្ឋាននីមួយៗ ។

ខ. អំពីចំណាយ

១. ចំណាយចរន្ត :

ចំណាយចរន្តត្រូវអនុវត្តអោយបានម៉ឺងម៉ាត់ ទៅតាមគោលការណ៍ និងនីតិវិធីដូចគ្នា នៃចំណាយថវិការដ្ឋដែលពោលគឺ ៖

– អំពីចំណាយបៀវត្សត្រូវអនុវត្តតាមរយៈភ្នាក់ងារបើកផ្តល់ ។ ចំពោះបៀវត្សមូលដ្ឋាន ប្រាក់កំរៃបុគ្គលិកអណ្តែត និងភ្នាក់ងារជាប់កិច្ចសន្យា ត្រូវអនុវត្តតាមសេចក្តីជូនដំណឹងលេខ ១៣៣៤.សជណ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដោយកាត់បន្ថយចំនួន ៥០ភាគរយ នៃចំនួនដែលបានព្រាងរួចហើយសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។ ចំណែកប្រាក់ឧបត្ថម្ភចំពោះ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមអនុក្រឹត្យ លេខ ២១៤ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានព្រាងនៅក្នុង អនុគណនី ៦៤៤២ (លាភការផ្សេងៗទៀតបុគ្គលិកមិនមែនក្របខ័ណ្ឌ)

– អំពីចំណាយតូចតាច និងចំណាយចាំបាច់បន្ទាន់ គឺត្រូវអនុវត្តតាមរដ្ឋទេយ្យបុរេប្រទានដែលកំណត់ឡើងដោយដីការបស់រាជធានី ខេត្ត។ ពេលដកប្រាក់ពីធនាគារ រដ្ឋទេយ្យករត្រូវមានបណ្ណដកប្រាក់ និងលិខិតឧទ្ទេសនាមរបស់អង្គភាព (កុំចាំបាច់ធ្វើលិខិតស្នើសុំច្បងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ) ។ ចំពោះការចំណាយតាមរយៈរដ្ឋទេយ្យបុរេប្រទាន សម្រាប់ថវិកាឆ្នាំ ២០១០នេះ អភិបាលរាជធានី ខេត្ត ត្រូវពិភាក្សាអោយបានល្អិតល្អន់ជាមួយប្រធានរតនាគាររាជធានី ខេត្ត និងប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ក្នុងការកំណត់ទំហំឥណទាន និងចំនួនជុំបង្វិល ដើម្បីធានាអោយឥណទានរដ្ឋទេយ្យបុរេប្រទានអាចបំពីបានទាន់ពេលវេលា ទាំងនៅរដ្ឋបាលថ្នាក់រាជធានី ខេត្តនិងទាំងនៅរដ្ឋបាលថ្នាក់ ក្រុង ស្រុក ខណ្ឌ ក្នុងពេលដែល ក្រុង ស្រុក ខណ្ឌ ពុំទាន់មានថវិការបស់ខ្លួនតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

– អំពីចំណាយចរន្តផ្សេងៗទៀត គឺត្រូវអនុវត្តទៅតាមនីតិវិធីទូទាត់ត្រង់ជូនអ្នកផ្គត់ផ្គង់ ក្រោយពេលដែលទំនិញ ឬសេវាទានា ត្រូវបានអនុវត្តរួចហើយ ។

– ចំពោះជំពូក ០៩(ចំណាយមិនបានគ្រោងទុក) រាជធានី ខេត្ត មិនត្រូវអនុវត្តចំណាយជំពូកនេះដោយផ្ទាល់ទេ ។ នៅពេលមានតំរូវការចំណាយរាជធានី ខេត្ត ត្រូវធ្វើសំណើសុំការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីបង្វែរឥណទានពីជំពូកនេះ ទៅជាប្រយោជន៍ដល់ជំពូកចំណាយដទៃទៀតទៅតាមតំរូវការចំណាយជាក់ស្តែងនីមួយៗ ជាពិសេសអាទិភាពសំរាប់តំរូវការប្រាក់បៀវត្ស និងការងារអភិវឌ្ឍន៍គុណប្រយោជន៍ រាជធានី ខេត្ត ។

– ដោយឡែក សម្រាប់ខេត្តបាត់ដំបង និងខេត្តសៀមរាប ឯកឧត្តមអភិបាលខេត្ត ត្រូវចេញដីកាផ្ទេរឥណទាន និងផ្ទេរភារៈការបស់ជូនអភិបាលក្រុងបាត់ដំបង និងក្រុងសៀមរាប អោយអនុវត្តនូវចំនួនឥណទានដែលខេត្តបានពិភាក្សា ឯកភាពជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចដែលបានបែងចែកនិងភ្ជាប់ជាមួយក្នុងសៀវភៅថវិការបស់ខេត្តបាត់ដំបង និងខេត្តសៀមរាបរួចហើយនោះ ។

២. ចំណាយជាមូលធន :

ចំពោះការចំណាយជាមូលធនគឺចែកចេញជាពីរ ៖

ទី១.ចំណាយសម្រាប់មូលនិធិបម្រុង :

ក្នុងពេលអនុវត្តរាជធានី ខេត្ត ត្រូវធ្វើអាណត្តិដោយគ្រាន់តែភ្ជាប់តាមនូវគំរោងកម្មវិធីវិនិយោគសាធារណៈ នៃហិរញ្ញប្បទានពីក្រៅប្រទេសតែប៉ុណ្ណោះ ។ រតនាគាររាជធានី ខេត្ត ត្រូវបើកផ្តល់ ឬផ្ទេរឥណទាននេះ ទៅក្នុងគណនីម្ចាស់ជំនួយនៅរតនាគាររាជធានី ខេត្ត ឬ ធនាគារ (បើមាន) ។

ទី២.ចំណាយវិនិយោគ :

ចំណាយវិនិយោគ ទោះជាហិរញ្ញប្បទានដោយថវិការាជធានី ខេត្ត ឬហិរញ្ញប្បទានដោយថវិការដ្ឋឧបត្ថម្ភក៏ដោយក៏ ត្រូវតែបំពេញបែបបទ និងអនុវត្តអោយបានត្រឹមត្រូវទៅតាមនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន និងធ្វើអាណត្តិទូទាត់អោយបានត្រឹមត្រូវតាមការិយបរិច្ឆេទដែលបានកំណត់ក្នុងសៀវភៅបន្ទុក ឬ កិច្ចសន្យា ។

៣. ចំណាយបន្ថែមលើសពីគំរោងចំណាយថវិការាជធានី ខេត្តប្រចាំឆ្នាំ :

យោងប្រការ ១២ នៃ ប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីបទបញ្ញាថវិការបស់រាជធានី ខេត្ត បានចែងថា នៅក្នុងឆ្នាំថវិកាប្រសិនបើចំណូលជាក់ស្តែងនៃថវិការបស់រាជធានី ខេត្ត បានកើនឡើងខ្ពស់ជាង ពីគំរោងចំណូលប្រចាំឆ្នាំ ដែលបានគ្រោងទុកនោះឥណទានចំណាយថវិកាអាចត្រូវបង្កើនឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទៅតាមកំរិតចំណូលលើសដែលបានចុះកិច្ចបញ្ជីការ ។

ដូច្នេះ នៅត្រីមាសទី ៤រាជធានី ខេត្ត ត្រូវពិនិត្យការអនុវត្តចំណូលរបស់ខ្លួន ដោយមានមូលដ្ឋានជាក់លាក់ដែលអាចប្រមូលចំណូលបានយ៉ាងពិតប្រាកដ រួចប្រៀបធៀបជាមួយគំរោងចំណូលប្រចាំឆ្នាំ ។ ប្រសិនបើមានចំណូលលើសពីគំរោងចំណូលប្រចាំឆ្នាំរាជធានី ខេត្ត អាចស្នើសុំបន្ថែមលើគំរោងចំណាយប្រចាំឆ្នាំ សម្រាប់ចំណាយជាគុណប្រយោជន៍របស់រាជធានី ខេត្ត ដែលជាចំណាយសំរាប់វិនិយោគអភិវឌ្ឍន៍រាជធានី ខេត្ត ហើយរាជធានី ខេត្ត ត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវគំរោងចំណាយលំអិតតាមការដ្ឋាននីមួយៗផង ។

គ. ការបង្វែរឥណទាន

ការបង្វែរ (និយ័តភាព) ឥណទានត្រូវបានអនុញ្ញាតដោយអនុវត្តចាប់ពីត្រីមាសទី ២ ។ ក្នុងករណីមានការចាំបាច់និយ័តភាពថវិកាពីអនុគណនីមួយ ទៅអនុគណនីមួយ ពីគណនីមួយ ទៅគណនីមួយ និងពីជំពូកមួយ ទៅជំពូកមួយផ្សេងទៀតនោះ រាជធានី ខេត្ត ត្រូវធ្វើសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍អនុវត្តចំណាយដើមឆ្នាំនិងរបាយការណ៍ចាំន់ស្មានចំណាយចុងឆ្នាំព្រមទាំងឯកសារផ្សេងៗ ទៀតដែលពាក់ព័ន្ធការស្នើសុំនិយ័តភាព ។

ឃ. ការរៀបចំកម្មវិធីចំណូល ចំណាយ

ផ្អែកលើគំរោងថវិកាប្រចាំឆ្នាំ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានប្រកាសជូនរាជធានី ខេត្ត ទាំងអស់ត្រូវរៀបចំកម្មវិធីចំណូល ចំណាយថវិកាប្រចាំត្រីមាស និងត្រូវផ្ញើកម្មវិធីចំណូល ចំណាយនោះទៅរតនាគាររាជធានី ខេត្ត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ យ៉ាងយូរបំផុតមួយសប្តាហ៍នៃដើមត្រីមាសនីមួយៗ ។ ដោយឡែកសម្រាប់ត្រីមាសទី ២ ទី ៣ និងទី៤ ពេលផ្ញើកម្មវិធីចំណូល ចំណាយប្រចាំត្រីមាសមកក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ គឺដាច់ខាតត្រូវតែភ្ជាប់មកជាមួយនូវរបាយការណ៍ស្តីពីការអនុវត្តថវិកានៃត្រីមាសមុន។ កម្មវិធីចំណូល ចំណាយប្រចាំត្រីមាស គឺជាឯកសារគោល ដើម្បីវិភាគក្នុងការផ្តល់ឧបត្ថម្ភធនសុល្យភាពពីថវិការដ្ឋ ។

ក្នុងការអនុវត្តថវិការាជធានី ខេត្ត ក្រុមហិរញ្ញវត្ថុត្រូវធ្វើជាលេខាធិការអោយអភិបាលរាជធានី ខេត្ត ក្នុងការរៀបចំរាល់សំណុំលិខិត ឯកសារទាំងអស់ដែលពាក់ព័ន្ធដល់ការចំណាយហិរញ្ញវត្ថុ ថវិកា ដើម្បីជំរុញអោយការអនុវត្តចំណូល និងចំណាយថវិការាជធានី ខេត្ត សំរេចបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព។

ខាងលើនេះ គឺជាការណែនាំបន្ថែមក្នុងកិច្ចប្រតិបត្តិការថវិការាជធានី ខេត្ត អោយចំទិសដៅ និងមានប្រសិទ្ធភាពសំរាប់ការគ្រប់គ្រងឆ្នាំ ២០១០ ដោយខ្សែរប្រកាសណែនាំស្តីពីកិច្ចប្រតិបត្តិការអនុវត្តថវិការាជធានី ខេត្ត លេខ ៦០៥ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលមិនផ្ទុយនឹងប្រកាសនេះ នៅតែរក្សាសុពលភាពដដែល ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ ២០០៩

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

<u>កន្លែងទទួលៈ</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

  (ដើម្បីជូនជ្រាប)

- អគ្គនាយកដ្ឋានរតនាគារជាតិ
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- គ្រប់រតនាគាររាជធានី ខេត្ត
- គ្រប់សាខាពន្ធដាររាជធានី ខេត្ត

  (ដើម្បីអនុវត្ត)

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០០៧.......សហវ.....

សារាចរណែនាំ

ស្តីពី

ការគ្រប់គ្រងការនាំចេញ នាំចូលទំនិញមួយចំនួនតាមរូបភាពតូច

៣៥ • ៦២

កន្លងមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានសង្កេតឃើញនូវបាតុភាពអសកម្មមួយចំនួនដែលបង្កឡើងដោយក្រុមបុគ្គលខ្លះ តាមរយៈការបង្កើតនូវស្តង់ទំនិញតាមរូបភាពផ្សេងៗ រួចដំណើរការអាជីវកម្មស្រដៀងរូបភាពផ្តាច់មុខ និងប្រមូលកំរៃពីអ្នកនាំចេញ- នាំចូលផ្សេងទៀត បង្កជាឧបសគ្គដល់អាជីវករទាំងនោះ ជាពិសេសពាក់ព័ន្ធនឹងមុខទំនិញឆាប់ខូច ដូចជា បន្លែ ផ្លែឈើ មើមឈើ និងផលិតផលកសិកម្មឆាប់ខូចផ្សេងទៀតរបស់អាជីវករតូចតាចៗ។

ក្នុងន័យនេះ ដើម្បីកាត់បន្ថយនូវបាតុភាពអសកម្មទាំងនេះ និងដោយយោងតាមចំណារដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៩ លើលិខិតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ៦០៦១ សហវ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩ ផងនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការកំណត់ និងណែនាំជាបណ្តោះអាសន្នដល់គ្រប់អង្គភាពគយ និងរដ្ឋាករ និងបុគ្គលពាក់ព័ន្ធនានា ដូចខាងក្រោម :

១. ត្រូវបន្តអនុវត្តឱ្យបានម៉ឹងម៉ាត់តាមបទបញ្ញត្តិច្បាប់ជាធរមាន ជាពិសេសសារាចរលេខ ០០៩ សហវ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងទំនិញនាំចូលគ្មានលក្ខណៈពាណិជ្ជកម្ម។

២. សេវាកម្មបំពេញបែបបទគយនាំចេញ- នាំចូលទំនិញជំនួសអ្នកដទៃ អាចធ្វើទៅបានតែដោយបុគ្គលដែលមានគុណវុឌ្ឍិជាជើងសារគយណាមួយប៉ុណ្ណោះ តាមបញ្ញត្តិជំពូក ៥ នៃច្បាប់ស្តីពីគយ។ បុគ្គលជាជើងសារគយ អាចប្រមូលកំរៃពីម្ចាស់ទំនិញពិត ទៅតាមការព្រមព្រៀងគ្នាជាមុន តាមករណីជាក់ស្តែងនីមួយៗ។

៣. សម្រួលអនុគ្រោះជូនរូបវន្តបុគ្គល ដែលធ្វើអាជីវកម្មនាំចេញ- នាំចូលតាមរូបភាពតូច មានតម្លៃគិតពន្ធសមមូលត្រឹម ៣០០ ដុល្លារអាមេរិកចុះ លើមុខទំនិញមួយចំនួន រួមមាន បន្លែ ផ្លែឈើ និងកសិផលប្រហាក់ប្រហែលផ្សេងទៀត ដែលមិនស្ថិតក្នុងបញ្ជីទំនិញហាមឃាត់ និងបញ្ជីទំនិញជាប់កម្រិតកំណត់ ជាធរមាន អាចបំពេញបែបបទគយដោយខ្លួនឯងបាន ទោះបីមាន ឬគ្មានលេខអត្តសញ្ញាណកម្មអាករលើតម្លៃបន្ថែមក្តី ដោយគ្រាន់តែធ្វើប្រកាសសុំតាមទម្រង់សង្ខេបដូចមានជូនភ្ជាប់មកជាមួយនេះ និងតម្កល់នូវច្បាប់ចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬឯកសារសំគាល់ខ្លួនផ្លូវការផ្សេងទៀត ដោយមានផ្តិតមេដៃស្តាំបញ្ជាក់ ព្រមទាំងចុះហត្ថលេខា

ចំពោះមុខមន្ត្រីមានសមត្ថកិច្ចជាប់ជាមួយ។ ករណីដូចនេះ ត្រូវបានអនុគ្រោះសិរាប់ការនាំចូល- នាំចេញតាមរូបភាពតូចៗ ដើម្បីចរាចរចែកចាយក្នុងប្រទេសជាក់ព័ន្ធ ទោះបីមានលក្ខណៈពាណិជ្ជកម្មក្តី ហើយតម្លៃគិតពន្ធលើមុខទំនិញទាំងនេះ ត្រូវបានកំណត់ដោយបូកបន្ថែម ១០% លើតម្លៃគិតពន្ធគយតាមបទបញ្ញត្តិជាធរមានដោយមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចនាមាត់ច្រកបំពេញបែបបទគយតែម្តង។

៤. ក្នុងករណីជួបប្រទះនូវការលំបាកនានាក្នុងពេលអនុវត្តតាមខ្លឹមសារខាងលើ ឬក្នុងករណីសង្កេតឃើញនូវបាតុភាពអសកម្មនានាបន្តទៀតនោះ បុគ្គលពាក់ព័ន្ធ ត្រូវរាយការណ៍ជាបន្ទាន់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងដោះស្រាយជូនឱ្យបានទាន់ពេលវេលា។

ទទួលបានសារាចរណែនាំនេះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវចាត់ចែងឱ្យមានការផ្សព្វផ្សាយទូលំទូលាយដល់អាជីវករតូចតាចដែលប្រកបរបរនាំចេញ- នាំចូលទំនិញដូចរៀបរាប់ខាងលើ ឱ្យបានយល់ពីនីតិវិធីសាមញ្ញនេះ ហើយជំរុញឱ្យមានការបំពេញកាតព្វកិច្ចពន្ធ អាករឱ្យបានត្រឹមត្រូវតាមបទបញ្ញត្តិច្បាប់ជាធរមាន ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១០ រហូត ដល់មានការសម្រេចជាថ្មី។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- គ្រប់សាលារាជធានី- ខេត្ត
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារ
  "ដើម្បីជ្រាប និងអនុវត្តតាមមុខការ"
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១០៨៩ ពណ.ចបព

ភ្នំពេញ ថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០០៩

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : ស៊ុន អ៊ូ ខុង
SHUN WU KONG Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 5666/09E ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោកស្រី DUONG THI HUYEN ប្រធានក្រុមប្រឹក្សាភិបាល
លោក HUYNH PETER QUANG អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៧.២០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ L ១០ ផ្លូវលេខ ២៦៥ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ៍ណ អាហរ៍ណទំនិញគ្រប់ប្រភេទ នាំចូលនិងផលិតសំភារៈបរិក្ខារពេទ្យ គ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-សេវាបោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ
-សេវាកាត់ត្រេចិញ្ចឹមនិងការលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខានិងត្រា

ចាម ប្រសិទ្ធ

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "

ស.៩ - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១០៥១ ពណ.ចបព

ភ្នំពេញថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០០៩

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ខេមបូឌាន ឡាន ខាង ជាង អេនជីនារីង**
CAMBODIAN LAN CANG JIANG ENGINEERING Co., Ltd

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 5682/09E** ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៩

មានទម្រង់ជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក HE GUOZHONG ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី ZHANG QIUFANG ពតិយជន អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០.000.000.000 រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១៥៤ ផ្លូវលេខ ២៤៥ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម :
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់ អាគារមជ្ឈមណ្ឌលពាណិជ្ជកម្ម និងឧស្សាហកម្ម
-សិក្សាគំរោងប្លង់ និងគូរប្លង់គ្រប់ប្រភេទ-តម្លើងជួសជុលបណ្តាញទឹកនិងអគ្គិសនី
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ
ពិសេសសំភារៈបរិក្ខារសំណង់ សំភារៈបរិក្ខារអគ្គិសនី និងអេឡិចត្រូនិច
កុំព្យូទ័រ សំភារៈបរិក្ខារ និងវត្ថុធាតុដើមគីមីប្រើអោយវិស័យកសិកម្ម និងឧស្សាហកម្ម
គ្រឿងឧបភោគបរិភោគ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញ
គ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាកម្មការងារជូនពលករខ្មែរទៅធ្វើការក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

កឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ស.ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១០៩៩ ពណ.ចបព

ភ្នំពេញថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៩

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

សាខាក្រុមហ៊ុនបរទេសមួយត្រូវបានចុះបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុនដើម : **BANK OF INDIA**

នាមករណ៍របស់សាខា : **ធនាគារ ឥណ្ឌា សាខាភ្នំពេញ**

Bank of India Phnom Penh Branch

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 519/09B** ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៩

២- នាយកសាខាក្រុមហ៊ុន : លោក **BALIARSINGH RAMESH CHANDRA**

៣- ទីស្នាក់ការសាខា : អាគារ IOC លេខ ២៥៤ (F4-ROI) មហាវិថីព្រះមុនីវង្ស សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ

៤- កម្មវត្ថុអាជីវកម្ម : -ប្រតិបត្តិការធនាគារ

៥- សញ្ជាតិក្រុមហ៊ុន : ឥណ្ឌា

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំដែលទាក់ទងទៅ នឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់សាខា ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តលម្រះបទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម_ស៊ីថន

ចម្លងជូន

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-ធនាគារជាតិ នៃកម្ពុជា
- អគ្គនាយកដ្ឋានរាជកិច្ច និង រសៅកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ភ.ស.ខ - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១១១១ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៩

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **វើក ស្ញួ គ្រុប**

WORKS SURE GROUP Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 5680/09E** ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៩

មានទម្រង់ជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **PONGSAK SAKEAW** ប្រធានក្រុមប្រឹក្សាភិបាល

លោក **ឈុន យុត្តិយាន** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១៦១ F ផ្លូវលេខ ៩០៧ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាដឹកជញ្ជូន និងចែកចាយទំនិញ
-សេវាយកតំរែដឹងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកដាក់របាយការណ៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល-ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន-ធនាគារជាតិ នៃកម្ពុជា
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ក.ជ.ន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១១១៦ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៦ ខែ ៣ ឆ្នាំ ២០០៩

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា ៖

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខណៈដូចខាងក្រោម ៖

១- នាមករណ៍របស់ក្រុមហ៊ុន : **ស៊ីវ ហ៊ុន អលង្ការ**

SIV HUN AKLAINKA Co., Ltd.

អគ្គលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 13325/09P ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩

មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន :

លោកស្រី	**ស៊ីវ ហ៊ុន**	ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី	**តាំង សេងណារី**	អភិបាល
លោក	**តាំង ម៉េង**	អភិបាល
លោក	**តាំង សេងមី**	អភិបាល
លោក	**តាំង សេងឈុន**	អភិបាល
លោក	**ស៊ុន នី**	អភិបាល
លោកស្រី	**តាំង សេងណាវី**	អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៧០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៦៥ Eo ផ្លូវលេខ ១២៦ សង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម ៖ ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ និងត្បូងថ្មមានតំលៃគ្រប់ប្រភេទ

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានភារកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.រដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

...ម_ស៊ីថន

<u>ចម្លងជូន</u>

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធនាគារជាតិនៃកម្ពុជា
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "

ស.៩ - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១១១៣ ពណ.ចបព

ភ្នំពេញថ្ងៃទី ១២ ខែ ៣ ឆ្នាំ ២០០៩

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ចំណាប់ យូ អេហ្វ អូ អ៊ីមផត & អិចផត**

CHAMNAB U. F. O IMPORT & EXPORT Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 13323/09P ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក ទ្រី ចំណាប់ ប្រធានក្រុមប្រឹក្សាភិបាល

លោក ហៀង ឌុស្សី អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ២១៨ បេ ផ្លូវលេខ ១៥០ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ ទីហរិណ អាហារីណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវា[illegible]

-សេវា[illegible]ដឹកជញ្ជូន

-សាងសង់ [illegible] អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗអភិបាលក្រុមហ៊ុនមានកាតព្វកិច្ចម៉កតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

[illegible] ស៊ីថន

<u>ចម្លងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល-ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន-ធនាគារជាតិ នៃកម្ពុជា
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងឃោសនាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

កឈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១១១៦ ពណ.ចបក

ភ្នំពេញថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា ៖

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខណៈដូចខាងក្រោម ៖

១- នាមករណ៍របស់ក្រុមហ៊ុន : **ហេបភី ថោន ត្រាវែល & ធួរ**
HAPPY TOWN TRAVEL & TOURS Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 13326/09P ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **តាំង ស៊ីវអាន** ប្រធានក្រុមប្រឹក្សាភិបាល
លោក **លី ចាន់ឌុខ** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៦៥៨ Eo វិថីកម្ពុជាក្រោម (១២៨) សង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការផ្គូសផ្គុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស [illegible]
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុនទៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

ម_ស៊ីផន

<u>ចម្លងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១១១៧ ពណ.ចបព

ភ្នំពេញថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៩

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **វេឡូកូ**
VELOCO Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 5679/09E ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៩
មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក ROBERT PIFFL ប្រធានក្រុមប្រឹក្សាភិបាល
លោក MARTIN LINHART អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១១៥ ផ្លូវលេខ ១៧៣ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្ដូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្ដូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស ... និងសេវាបញ្ជូនទំនិញ
-សេវាយកពត៌មានលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗអភិបាលក្រុមហ៊ុនមានភារកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គីម_ស៊ីថន

<u>ចម្លងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល-ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន-ធនាគារជាតិ នៃកម្ពុជា
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

កសន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១១៣៣ ៣ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០០៩

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ស៊ីសវើក**

CISWORK Co., Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 5690/09E ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩

មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ជន សុភា**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ២៥ A ផ្លូវលេខ ១៩៥៨ B សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការដួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការដូសដុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្តវីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

ចម្លងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល -ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "

សធ - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១១៣៤ ពណ.ចបព

ភ្នំពេញថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៩

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

សាខាក្រុមហ៊ុនបរទេសមួយត្រូវបានចុះបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុនដើម : BAYER THAI CO., LTD.

នាមករណ៍របស់សាខា : **សាខាក្រុមហ៊ុន បេយើរ ថៃ ខោ បេយើរ (ខេមបូឌា) ប្រែន**

Branch of BAYER THAI CO., LTD. known as

BAYER (CAMBODIA) BRANCH

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 520/09B ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩

២- នាយកសាខាក្រុមហ៊ុន : លោក MUNEEB UR REHMAN

៣- ទីស្នាក់ការសាខា : លេខ ១៦០ មហាវិថីម៉ៅសេទុង សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៤- កម្មវត្ថុអាជីវកម្ម : -ផលិត និងចែកចាយឱសថគ្រប់ប្រភេទ
-អាហរិណ នីហរិណទំនិញគ្រប់ប្រភេទ

៥- សញ្ជាតិក្រុមហ៊ុន : ថៃ

រាល់ដំណាច់ឆ្នាំនីមួយៗ នាយកសាខាក្រុមហ៊ុនមានភារកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់សាខា ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសេចក្តីស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

ក្រសួងពាណិជ្ជកម្ម

គឹម_ស៊ីថុន

<u>ចម្លងជូន:</u>

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-ក្រសួងសុខាភិបាល
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានពាណិជ្ជ និង [illegible]
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "ដូចការ"

ឯ.ម - ឯកសារ-កាលប្បវត្តិ

បោះពុម្ពនៅអគ្គនាយកដ្ឋាន
រាជកិច្ច និង សេវាកុំព្យូទ័រ
នៃទីស្ដីការគណៈរដ្ឋមន្ត្រី